ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអភិវឌ្ឍន៍ជនបទ

លេខ.....០០១/០២..... ក.អ.ជ

ភ្នំពេញ, ថ្ងៃទី..០៨..ខែ...មករា...ឆ្នាំ200.២

# ប្រកាស
## ស្តីពីការតែងតាំងមន្ត្រី បំរើការងារក្នុងអង្គភាពគាំទ្រគំរោង សំរាប់អនុវត្តគំរោង ក្នុងក្របខ័ណ្ឌឥណទានៃមូលនិធិអន្តរជាតិសំរាប់អភិវឌ្ឍន៍កសិកម្ម

## រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ន.ស / រកត / ១១៩៨ / ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការបង្កើតរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រម ន.ស / រកម / ០១៩៦ / ១២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការប្រកាសអោយប្រើនូវច្បាប់ ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ / បក ចុះថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញសេចក្តីសំរេចលេខ ១៧៩១ សសរ / អបជ ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ១៩៩៨ ស្តីពីការបែងចែកភារកិច្ច និង ការកំណត់របៀបរបបធ្វើការរបស់ថ្នាក់ដឹកនាំក្រសួងអភិវឌ្ឍន៍ជនបទ
- AIDE MEMORIE របស់ IFAD Appraisal Mission ជាមួយក្រសួងពាក់ព័ន្ធ និងភ្នាក់ងារជាដៃគូ ដែលបានចុះហត្ថលេខានៅថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០០ ។
- យោងតំរូវការចាំបាច់
- យោងលទ្ធផលរបស់គណៈកម្មការជ្រើសរើស ចុះថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០០១

## សំរេច

<u>ប្រការ១</u> : តែងតាំង **លោក កែវ ទិសិដ្ឋ** ជាមន្ត្រីហិរញ្ញវត្ថុ ដើម្បីបំរើការងារក្នុងអង្គភាពគាំទ្រគំរោង សំរាប់អនុវត្តគំរោងអភិវឌ្ឍន៍សហគមន៍មូលដ្ឋានជនបទ ក្នុងខេត្តកំពង់ធំ និងខេត្តកំពត ក្នុងក្របខ័ណ្ឌឥណទាន នៃមូលនិធិអន្តរជាតិសំរាប់អភិវឌ្ឍន៍កសិកម្ម ដែលមានស្នាក់ការនៅក្រសួងអភិវឌ្ឍន៍ជនបទ ។

<u>ប្រការ២</u> : សាមីជនដូចមានចែងក្នុងប្រការ១ មានភារកិច្ចទទួលខុសត្រូវ ក្នុងការអនុវត្តការងារក្នុងអង្គភាពគាំទ្រគំរោងសំរាប់អនុវត្តគំរោងក្នុងក្របខ័ណ្ឌឥណទាន នៃមូលនិធិអន្តរជាតិ សំរាប់អភិវឌ្ឍន៍កសិកម្ម ដូចមានចែងក្នុងឯកសារគំរោង ។

<u>ប្រការ៣</u> : រាល់សេចក្តីសំរេចណាដែលផ្ទុយពីសេចក្តីសំរេចនេះ ចាត់ទុកជានិរាករណ៍ ។

<u>ប្រការ៤</u> : អគ្គនាយកទាំងពីរ អគ្គាធិការ ខុទ្ទកាល័យ គ្រប់នាយកដ្ឋាន ក្រោមឱវាទក្រសួងគណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្តកំពង់ធំ និង ខេត្តកំពត គ្រប់មន្ទីរពាក់ព័ន្ធ នៃខេត្តទាំងពីរ និងសាមីជនដូចមានចែងក្នុងប្រការ ១ មានភារកិច្ចអនុវត្តតាមប្រកាសនេះអោយមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ឈឺ - ឈុន

**<u>កន្លែងទទួល</u>**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- លេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារសីលា
- សាលាខេត្តកំពង់ធំ និង កំពត
- មន្ទីរពាក់ព័ន្ធខេត្តទាំងពីរ
- អង្គការ IFAD,GTZ,WFP&AusAID
  " ដើម្បីជូនជ្រាប "
- ដូចមានចែងក្នុងប្រការ៣
  " ដើម្បីអនុវត្ត "
- ឯកសារ- កាលប្បវត្តិ